បណ្ណាល័យ
គ.ជ.អ.ប

រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សៀវភៅណែនាំ
# ស្តីពី
# ការអនុវត្តគណនេយ្យភាព
# របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ខែ កញ្ញា ឆ្នាំ២០១៥

library.ncdd.gov.kh
015392
354.968 ACC.SUB
sh: Training

បណ្ណាល័យ
គ.ជ.អ.ប

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខ: ០៥២.........../គ.ជ.អ.ប

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៥

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ឲ្យប្រើប្រាស់សៀវភៅណែនាំស្តីពី
## ការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ
## សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

- យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- យោងព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- យោងព្រះរាជក្រមលេខ នស/រកម ០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យោងព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១១ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា៧ មាត្រា៨ មាត្រា១២ មាត្រា១៥ មាត្រា១៧ និងបន្ថែមមាត្រា១២ស្ទួននៃអនុក្រឹត្យលេខ២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ២០១០-២០១៩
- យោងផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី២ (២០១៥-២០១៧)នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# សម្រេច

**ប្រការ ១.-**

ដាក់ឱ្យប្រើប្រាស់នូវ "សៀវភៅណែនាំស្តីពីការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ" ។

**ប្រការ ២.-**

រដ្ឋបាលរាជធានី រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ និងមន្ត្រីនៃសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទាំងអស់ត្រូវពង្រឹងការអនុវត្តខ្សែគណនេយ្យភាពរបស់ខ្លួនស្របតាមការកំណត់ក្នុងសៀវភៅណែនាំនេះ ។

**ប្រការ ៣.-**

អង្គភាពវិភាគ និងអភិវឌ្ឍន៍គោលនយោបាយនៃលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិមានភារកិច្ចផ្តល់ការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តខ្សែគណនេយ្យភាពដែលបានកំណត់ ។

**ប្រការ ៤.-**

សេចក្តីសម្រេចនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**រដ្ឋលេខាធិការក្រសួងមហាផ្ទៃ**
**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

ស័ក់ សេដ្ឋា

**ចម្លងជូន**

- ក្រសួង ស្ថាប័នសមាជិក គ.ជ.អ.ប (ដើម្បីជ្រាប)
- ដូចប្រការ ២ និង ប្រការ ៣ (ដើម្បីអនុវត្ត)
- ឯកសារ-កាលប្បវត្តិ

# មាតិកាអត្ថបទ


## ១. ទិដ្ឋភាពទូទៅនៃការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

១.១. សេចក្តីផ្តើម ១

១.២. និយមន័យ ៤

១.៣. គោលបំណង ៦

១.៤. ប្រភេទនៃគណនេយ្យភាព ៦

## ២. ក្របខ័ណ្ឌច្បាប់សម្រាប់ការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

២.១. ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ១៥

២.២. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ១៦

២.៣. ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ១៦

២.៤. លិខិតបទដ្ឋានគតិយុត្តនានា ១៧

## ៣. ការអនុវត្តគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ

៣.១. គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ ២១

៣.២. គណនេយ្យភាពផ្ទៃក្នុង ៣២

៣.៣. គណនេយ្យភាពរបស់រដ្ឋបាលចំពោះប្រជាពលរដ្ឋ ៤១

៣.៤. គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ៤៤

# ១. ទិដ្ឋភាពទូទៅនៃការអនុវត្ត គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

## ១.១. សេចក្តីផ្តើម

ការអភិវឌ្ឍរដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យក្លាយទៅជាស្ថាប័នប្រជាធិបតេយ្យ ដែលស្ថាប័នទាំងនោះត្រូវធ្វើជាតំណាង និងឆ្លើយតបចំពោះតម្រូវការនានារបស់ប្រជាពលរដ្ឋ គឺជាគោលបំណងចម្បងមួយនៃកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ដោយសារអភិបាលកិច្ចល្អបានរួមចំណែកយ៉ាងធំធេងក្នុងការលើកកម្ពស់ការផ្តល់សេវា និងការអភិវឌ្ឍមូលដ្ឋាន ហេតុនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវលើកកម្ពស់ការអនុវត្តនូវគោលការណ៍សំខាន់ៗនៃអភិបាលកិច្ចល្អ ដោយត្រូវធ្វើយ៉ាងណាឲប្រជាពលរដ្ឋបានចូលរួមក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចនោះ ព្រមទាំងត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាផងដែរ។

នៅក្នុងប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនៃប្រទេសកម្ពុជា ការធ្វើគណនេយ្យភាពត្រូវបានអនុវត្តតាមរបៀបខុសៗគ្នា ប៉ុន្តែមានគោលបំណងដូចគ្នា។ ចាប់តាំងពីឆ្នាំ២០០២ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋរបស់ខ្លួន នៅរៀងរាល់៥ឆ្នាំម្តង។ ចាប់តាំងពីឆ្នាំ២០០៩ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌក៏ត្រូវបានបង្កើតឡើងតាមរយៈការបោះឆ្នោតអសកល ដោយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅរៀងរាល់៥ឆ្នាំម្តងផងដែរ។ ផ្អែកតាមច្បាប់រៀបចំ

អង្គការ ក្រុមប្រឹក្សាត្រូវបំពេញមុខងារជាតំណាងប្រជាពលរដ្ឋនៅក្នុងការធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ ព្រមទាំងធ្វើការត្រួតពិនិត្យទៅលើការអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ដែលបានដាក់ចេញផងដែរ។

គណៈអភិបាល មានភារកិច្ចអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ដើម្បីចាត់ចែងកិច្ចការរដ្ឋបាល និងត្រួតពិនិត្យមើលកិច្ចការប្រចាំថ្ងៃរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ គណៈអភិបាលមានគណនេយ្យភាពចំពោះក្រុមប្រឹក្សា ក្នុងការអនុវត្តនូវសេចក្តីសម្រេច និងដីការបស់ក្រុមប្រឹក្សា។ នៅពេលដែលលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានដាក់ឱ្យប្រើប្រាស់ ក្រុមប្រឹក្សានឹងទទួលបាននូវសិទ្ធិអំណាចក្នុងការគ្រប់គ្រង ការចាត់ចែង ការជ្រើសរើស ការតែងតាំង ការលើកសរសើរ និងការដាក់វិន័យលើបុគ្គលិករបស់ខ្លួន។ ក្នុងអំឡុងពេលនៃការអនុវត្តផអ៣ទី១ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិបានទទួលការបណ្តុះបណ្តាល ការប្រឹក្សាយោបល់ និងការពិគ្រោះយោបល់ជាច្រើន ដើម្បីគាំទ្រក្នុងការអនុវត្តនូវមុខងាររបស់ខ្លួន។ ក្នុងការអនុវត្តជាក់ស្តែង ទោះបីមានការរីកចម្រើនជាច្រើនក៏ដោយ ក៏ប៉ុន្តែសមត្ថភាពរបស់ក្រុមប្រឹក្សា នៅក្នុងការអនុវត្តសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ និងការត្រួតពិនិត្យមើលពីលើនៅមានកម្រិតនៅឡើយ។

ក្រុមប្រឹក្សាឃុំ សង្កាត់មានការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងជា

ប្រចាំជាមួយប្រជាពលរដ្ឋរបស់ខ្លួន។ ដោយឡែក ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌពុំសូវមានការប្រាស្រ័យទាក់ទងដោយផ្ទាល់ និងជាប្រចាំជាមួយប្រជាពលរដ្ឋឡើយ។

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានគោលបំណងធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានស្វ័យភាពខ្ពស់។ ទោះបីយ៉ាងនេះក៏ដោយ ក៏រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែមានគណនេយ្យភាពចំពោះក្របខ័ណ្ឌច្បាប់ដោយត្រូវគោរពតាមគោលការណ៍ នីតិវិធី និងបទដ្ឋាននៃការផ្តល់សេវាដែលកំណត់ដោយក្រសួង ស្ថាប័ននានា។ បច្ចុប្បន្នសេចក្តីណែនាំពាក់ព័ន្ធនឹងរបៀបចាត់ចែង គ្រប់គ្រង និងពង្រឹងការអនុវត្តតាមរយៈដំណើរការធ្វើអធិការកិច្ចកំពុងត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។

យោងតាមមាត្រា៣៤ ផ្នែកទី២ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថា “ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់ អំពីជម្រើសជាអាទិភាពដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ រួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាល និង

អភិបាល”។

ជាមួយគ្នានេះ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិប-តេយ្យនៅថ្នាក់ក្រោមជាតិទាមទារឲមានការបង្កើតនូវខ្សែគណនេយ្យភាពថ្មី ការលើកកម្ពស់ការយល់ដឹង និងការបង្កើតប្រព័ន្ធ នីតិវិធី និងយន្តការទាំងឡាយដើម្បីធានាថា សិទ្ធិរបស់ប្រជាពលរដ្ឋត្រូវបានការពារ សំឡេងប្រជាពលរដ្ឋត្រូវបានដឹងឮ និងធនធាននានាត្រូវបានប្រើប្រាស់ស្របតាមច្បាប់។

តាមន័យនេះ ការពង្រឹងការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាកត្តាគន្លឹះមួយក្នុងការធានាឲការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យទទួលបានជោគជ័យស្របតាមទស្សនវិស័យ ដូចដែលបានកំណត់ក្នុងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។

## ១.២. និយមន័យ

គណនេយ្យភាព ត្រូវបានគេឱ្យនិយមន័យផ្សេងៗគ្នាជាច្រើនអាស្រ័យតាមស្ថានភាពជាក់ស្តែង។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ នៅក្នុងបរិបទនៃកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ គណនេយ្យភាព ត្រូវបានកំណត់និយមន័យស្រដៀងៗគ្នាដូចខាងក្រោម ៖

- សៀវភៅកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិកំណត់ថា “គណនេយ្យភាព គឺជាកាតព្វកិច្ចរបស់អ្នក ដែលទទួលបាននូវការទទួលខុសត្រូវ និង

សិទ្ធិអំណាចដើម្បីឆ្លើយបំភ្លឺ និងទទួលខុសត្រូវចំពោះទង្វើនានារបស់ខ្លួន រួមទាំងផលវិបាកដែលកើតឡើងពីទង្វើទាំងនោះ”។

- សៀវភៅ ផអពទី២ បានកំណត់ថា “គណនេយ្យភាព គឺជាកាតព្វកិច្ចនៃអ្នកអនុវត្តសិទ្ធិអំណាចក្នុងការឆ្លើយបំភ្លឺអំពីសកម្មភាពនានារបស់ខ្លួនចំពោះអាជ្ញាធរមានសមត្ថកិច្ចណាមួយ ដែលអាចដាក់នូវពិន័យក្នុងករណីខកខានមិនបានអនុវត្ត។
- សៀវភៅអភិបាលកិច្ចល្អសម្រាប់ក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ ២០០៥ កំណត់ថា “គណនេយ្យភាព គឺជាការអនុវត្តតួនាទី និងភារកិច្ចនៅក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេចចិត្ត និងអនុវត្តសេចក្ដីសម្រេចចិត្តនោះ ដោយមានការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន រាយការណ៍ ព្រមទាំងបញ្ជាក់ពីមូលហេតុនូវអ្វីដែលខ្លួនបានសម្រេច និងអនុវត្ត”។

គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ សំដៅលើការអនុវត្តគណនេយ្យភាពរបស់អង្គដែលកើតឡើងពីការបោះឆ្នោត (ដោយផ្ទាល់ ឬប្រយោល) ចំពោះប្រជាពលរដ្ឋទូទៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

**ឧទាហរណ៍ ៖** ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដែលកើតចេញពីការបោះឆ្នោត ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

១.៣. គោលបំណង

គោលបំណងនៃការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺដើម្បី ៖

- ធានាឲមានប្រសិទ្ធភាពនៃការធ្វើសេចក្តីសម្រេចចិត្ត និងអនុវត្តសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបម្រើឆន្ទៈ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ធានាឲមានភាពជាតំណាងសាធារណៈយ៉ាងពិតប្រាកដ
- ធានាឲមានប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ
- ពង្រឹងអភិបាលកិច្ចមូលដ្ឋាន និងការអភិវឌ្ឍមូលដ្ឋាន។

១.៤. ប្រភេទនៃគណនេយ្យភាព

ប្រភេទផ្សេងៗនៃគណនេយ្យភាព អាចមានដូចជា ៖

**១.៤.១. គណនេយ្យភាពផ្ទៃក្នុង**

គណនេយ្យភាពផ្ទៃក្នុង សំដៅទៅលើគណនេយ្យភាពនៅក្នុងអង្គការចាត់តាំងមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនៅក្នុងរង្វង់រដ្ឋបាលមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងបរិបទនៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ការពង្រឹងខ្សែគណនេយ្យភាពផ្ទៃក្នុងសំដៅទៅលើការរៀបចំវិធានការ យន្តការ និងនីតិវិធីនានាសម្រាប់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា ក្រុមប្រឹក្សា (ជាអង្គជាប់ឆ្នោត) គឺ



បណ្ណាល័យ
គ.ជ.អ.ប

ជាអង្គទទួលខុសត្រូវកំពូលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អាចធ្វើសេចក្តីសម្រេចផ្អែកតាមតម្រូវការរបស់ប្រជាពលរដ្ឋ មានលទ្ធភាពត្រួតពិនិត្យ និងណែនាំដល់គណៈអភិបាល និងអង្គភាពនានា ដែលអនុវត្តសេចក្តីសម្រេចរបស់ខ្លួន។ គណនេយ្យភាពផ្ទៃក្នុងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិអាចមានដូចជា ៖

- គណនេយ្យភាពរបស់គណៈអភិបាលចំពោះក្រុមប្រឹក្សា
- គណនេយ្យភាពរបស់គណៈកម្មាធិការនានាចំពោះក្រុមប្រឹក្សា
- គណនេយ្យភាពរបស់អភិបាលរងចំពោះអភិបាល
- គណនេយ្យភាពរបស់នាយក នាយករងរដ្ឋបាលចំពោះក្រុមប្រឹក្សា ឬចំពោះគណៈអភិបាល
- គណនេយ្យភាពរបស់នាយកទីចាត់ការចំពោះនាយករដ្ឋបាល
- គណនេយ្យភាពរបស់មន្ត្រីចំពោះប្រធានការិយាល័យ
- គណនេយ្យភាពរវាងស្មៀនឃុំ ជាមួយមេឃុំ
- ...។ល។

**ឧទាហរណ៍ ៖** ក្រុមប្រឹក្សាស្រុកបានអនុម័តគោលការណ៍ណែនាំផ្នែកគោលនយោបាយសម្រាប់ណែនាំដល់ការរៀបចំផែនការអភិវឌ្ឍស្រុក។ ជាមួយគ្នានេះ ក្រុមប្រឹក្សាក៏បានអនុម័តប្រតិទិនសម្រាប់ការកសាងផែនការអភិវឌ្ឍស្រុកផងដែរ។ បន្ទាប់ពីទទួលការអនុម័តពីក្រុមប្រឹក្សា អភិបាលស្រុកមានភារកិច្ចក្នុងការដឹកនាំ ចាត់ចែងរៀបចំការកសាងផែនការអភិវឌ្ឍស្រុក។ ក្នុងការអនុវត្តសេចក្តីសម្រេចនេះ អភិបាលត្រូវមានគណនេយ្យភាព

ចំពោះក្រុមប្រឹក្សារបស់ខ្លួន ដោយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាអំពីដំណើរការ និងលទ្ធផលនៃការអនុវត្ត ឬត្រូវឆ្លើយបំភ្លឺ និងបកស្រាយយ៉ាងសមហេតុផលជូនក្រុមប្រឹក្សា ប្រសិនបើក្រុមប្រឹក្សាស្នើសុំការបំភ្លឺណាមួយ។

**១.៤.២. គណនេយ្យភាពអន្តររដ្ឋបាល**

**ក). គណនេយ្យភាពអន្តររដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ** ៖ សំដៅលើគណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ឬរវាងអង្គការចាត់តាំងនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលមានប្រភេទដូចគ្នា ឬប្រភេទផ្សេងគ្នា។ គោលបំណងចម្បងនៃការពង្រឹងគណនេយ្យភាពអន្តររដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺដើម្បីលើកកម្ពស់ការឆ្លើយតប ការគាំទ្រ និងគណនេយ្យភាពរបស់ក្រុមប្រឹក្សានានាចំពោះក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គណនេយ្យភាពអន្តររដ្ឋបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនេះ អាចមានដូចជា ៖

- គណនេយ្យភាពរបស់រដ្ឋបាលរាជធានីចំពោះរដ្ឋបាលសង្កាត់
- គណនេយ្យភាពរបស់ក្រុមប្រឹក្សាស្រុកចំពោះក្រុមប្រឹក្សាឃុំ សង្កាត់
- គណនេយ្យភាពរវាងគណៈអភិបាលរាជធានី ខេត្ត គណៈអភិបាលក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់

- ...។ល។

**ឧទាហរណ៍ ៖** ក្នុងដំណើរការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលថ្នាក់ស្រុក រដ្ឋបាលស្រុកតម្រូវឱយឃុំនីមួយៗក្នុងដែនសមត្ថកិច្ចរបស់ខ្លួនផ្ញើគម្រោងវិនិយោគនានា ដែលហួសពីសមត្ថភាពធនធានដែលខ្លួនមានមកស្រុក ដើម្បីរៀបចំចាត់អាទិភាព និងរៀបចំគម្រោងវិនិយោគបីឆ្នាំរំកិលរបស់ស្រុក។ ឃុំ "ក" បានផ្ញើគម្រោងចំនួន០៥គម្រោងមកស្រុក។ បន្ទាប់ពីចាត់អាទិភាព មានគម្រោងរបស់ឃុំ "ក" តែ០១ប៉ុណ្ណោះត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីវិនិយោគក្នុងឆ្នាំខាងមុខរបស់ស្រុក។ ក្នុងករណីនេះ ក្រុមប្រឹក្សាឃុំ "ក" អាចស្នើសុំការឆ្លើយបំភ្លឺពីក្រុមប្រឹក្សាស្រុកអំពីមូលហេតុ ដែលគម្រោងរបស់ខ្លួនភាគច្រើនមិនត្រូវបានឆ្លើយតប។ ដូច្នេះ ក្រុមប្រឹក្សាស្រុក ត្រូវធ្វើការឆ្លើយតបដោយសមហេតុផលអំពីមូលហេតុ ដែលគម្រោងរបស់ឃុំ "ក" ភាគច្រើនមិនត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ស្រុក។

**ខ). គណនេយ្យភាពរវាងមន្ទីរ អង្គភាព ជាមួយក្រុមប្រឹក្សា** សំដៅលើគណនេយ្យភាពរវាងមន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នជាមួយនឹងក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ គឺជាតំណាងប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដូច្នេះ ក្រុមប្រឹក្សាអាចស្នើឱមន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នឆ្លើយបំភ្លឺនានាពាក់ព័ន្ធនឹងការផ្តល់សេវាជូនប្រជាពលរដ្ឋ ឬនៅពេលមានបណ្តឹងតវ៉ា ឬមានការស្នើសុំការបំភ្លឺណាមួយពីប្រជាពលរដ្ឋ។ ជាមួយគ្នានេះ ក្រុមប្រឹក្សាក៏អាចលើកឡើងអំពីបញ្ហា និងតម្រូវការនានារបស់ប្រជា

ពលរដ្ឋជូនដល់មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័ន ដើម្បីចាត់វិធានការឆ្លើយតប និងដោះស្រាយតាមជំនាញ ឬវិស័យនីមួយៗ។ បន្ទាប់ពីទទួលបានបញ្ហា និងតម្រូវការពីក្រុមប្រឹក្សា មន្ទីរ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នត្រូវរៀបចំ និងឆ្លើយតប ឬដោះស្រាយ ព្រមទាំងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាវិញ អំពីការអនុវត្តការឆ្លើយតប ឬការដោះស្រាយទាំងនោះ។

គណនេយ្យភាពអន្តររដ្ឋបាល អាចហៅម្យ៉ាងទៀតថា គណនេយ្យភាពខ្សែទទឹង។

**ឧទាហរណ៍**

- មន្ទីរសុខាភិបាលខេត្តមានគណនេយ្យភាពចំពោះរដ្ឋបាលខេត្ត អំពីការអនុវត្តវិធានការទប់ស្កាត់ការរីករាលដាលជំងឺរបេង
- ការិយាល័យអប់រំ យុវជន និងកីឡាស្រុកមានគណនេយ្យភាព ចំពោះរដ្ឋបាលស្រុកអំពីបញ្ហាកុមារបោះបង់ចោលការសិក្សា។

### ១.៤.៣. គណនេយ្យភាពចំពោះប្រជាពលរដ្ឋ

គណនេយ្យភាពចំពោះប្រជាពលរដ្ឋ សំដៅទៅលើគណនេយ្យភាព រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន តាមរយៈការរៀបចំឱ្យមានវិធានការ យន្តការ និងនីតិវិធីនានាសម្រាប់ធានាឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ នៅក្នុងដំណើរការអភិបាលកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ គណនេយ្យភាពចំពោះប្រជាពលរដ្ឋ ដូចគ្នានឹងគណនេយ្យភាពពីលើទៅក្រោម ឬគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ដែលក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋអំពី

ជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ដោយធានាបាននូវការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយក្រុមប្រឹក្សាក៏ត្រូវទទួលខុសត្រូវរាល់សេចក្តីសម្រេច និងការអនុវត្តសេចក្តីសម្រេចរបស់ខ្លួនផងដែរ។

**ឧទាហរណ៍ ៖** ក្រុមប្រឹក្សាឃុំ គឺអង្គដែលកើតចេញពីការបោះឆ្នោតដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាឃុំដែលកើតចេញពីការបោះឆ្នោតនេះ មានភារកិច្ចចម្បងក្នុងការចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាព សម្រាប់បំពេញសេចក្តីត្រូវការនានារបស់ប្រជាពលរដ្ឋ។ ក្នុងការអនុវត្តតួនាទីរបស់ខ្លួន ក្រុមប្រឹក្សាឃុំ “គ” បានអនុម័តដីកាស្តីពីការប្រើប្រាស់បឹងធម្មជាតិ ដោយត្រូវហាមឃាត់រាល់សកម្មភាពប្រើប្រាស់ថ្នាំពុលគីមីកសិកម្មនៅជុំវិញមាត់បឹង ដែលអាចនឹងបង្កផលប៉ះពាល់ដល់គុណភាពទឹក និងសត្វដែលរស់នៅក្នុងទឹកបឹង។ ដីកាដែលបានដាក់ឱ្យអនុវត្តនេះ បានធ្វើឱ្យកសិករដាំបន្លែជុំវិញបឹងមិនសប្បាយចិត្ត ហើយបានមកតវ៉ានៅមុខសាលាឃុំ។ មេឃុំ “គ” បានធ្វើការឆ្លើយបំភ្លឺជូនប្រជាកសិករទាំងនោះ ដោយបញ្ជាក់អំពីមូលហេតុច្បាស់លាស់ និងសម-ហេតុផល ដែលអាចឱ្យកសិករទាំងនោះទទួលយកបាន។ តាមរយៈការប្តឹង តវ៉ានេះ ឃុំអាចរកដំណោះស្រាយសមស្រប តាមមធ្យោបាយផ្សេងៗទៀតសម្រាប់អ្នកដែលទទួលផលប៉ះពាល់នេះ។

### ១.៤.៤. គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល

គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល សំដៅទៅលើ គណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយក្រសួង ស្ថាប័នថ្នាក់ជាតិ ឬរវាង

មន្ទីរ អង្គភាពរបស់ក្រសួង ស្ថាប័ន ដែលប្រតិបត្តិនៅថ្នាក់ក្រោមជាតិ ជាមួយក្រសួង ស្ថាប័នសាមី។ គណនេយ្យភាពប្រភេទនេះ អាចហៅម្យ៉ាងទៀតថា គណនេយ្យភាពខ្សែបណ្តោយ។

**ឧទាហរណ៍ ៖**

- ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា
- ប្រធានមន្ទីរកសិកម្មខេត្តត្រូវមានគណនេយ្យភាពចំពោះរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ
- ប្រធានការិយាល័យអប់រំ យុវជន និងកីឡាស្រុកត្រូវមានគណនេយ្យភាពចំពោះប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត។

ក្រៅពីប្រភេទគណនេយ្យភាពដូចបានរៀបរាប់ខាងលើ ក៏នៅមានប្រភេទគណនេយ្យភាពផ្សេងៗទៀត ដូចជា ៖

- **គណនេយ្យភាពផ្នែករដ្ឋបាល** ៖ សំដៅលើគណនេយ្យភាព ដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធគ្រប់គ្រង នីតិវិធីស្តង់ដារ និងនិយាមការងាររបស់បុគ្គល និងអង្គការចាត់តាំងតាមឋានានុក្រម។
- **គណនេយ្យភាពផ្នែកហិរញ្ញវត្ថុ** ៖ សំដៅទៅលើគណនេយ្យភាពដែលពាក់ព័ន្ធនឹងការរៀបចំប្រព័ន្ធ និងនីតិវិធីគ្រប់គ្រងថវិកា និងហិរញ្ញវត្ថុ ស្របទៅតាមច្បាប់ និងគោលការណ៍ហិរញ្ញវត្ថុ។
- **គណនេយ្យភាពសង្គម** ៖ គណនេយ្យភាពសង្គមសំដៅលើសកម្មភាព ឬយន្តការនានា ដែលប្រជាពលរដ្ឋអាចប្រើប្រាស់ដើម្បីទាមទារឲរដ្ឋមានគណនេយ្យភាពចំពោះខ្លួន ព្រមទាំង

សកម្មភាពនានារបស់រដ្ឋាភិបាល សង្គមស៊ីវិល និងតួអង្គដទៃទៀតក្នុងការលើកកម្ពស់ការអនុវត្តសកម្មភាព និងយន្តការទាំងនោះ។ តាមន័យនេះ គណនេយ្យភាពសង្គម គឺជាដំណើរការនៃការផ្សារភ្ជាប់ទំនាក់ទំនងដ៏ល្អប្រសើររវាងប្រជាពលរដ្ឋ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ហើយក៏ជាមធ្យោបាយមួយ ដែលបន្សុីគ្នារវាងគោលការណ៍ទាំងឡាយនៃអភិបាលកិច្ច ដែលក្នុងនោះរាល់ការធ្វើសេចក្ដីសម្រេចចិត្ត និងការអនុវត្តសកម្មភាពជាសាធារណៈនានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយត្រូវផ្ដល់ឱកាសឲ្យប្រជាពលរដ្ឋ និងតំណាងរបស់ពួកគាត់អាចការពារនូវផលប្រយោជន៍របស់ខ្លួន និងពិនិត្យតាមដានលើការបំពេញការងាររបស់ក្រុមប្រឹក្សា មន្ត្រីរដ្ឋបាល និងអ្នកផ្ដល់សេវាកម្មនានាដែលនៅមូលដ្ឋាន។ គណនេយ្យភាពសង្គម ក្នុងកិច្ចដំណើរការកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ មានគោលបំណងផ្ដល់នូវសិទ្ធិអំណាចដល់ប្រជាពលរដ្ឋ សហគមន៍មូលដ្ឋាន ជាពិសេសក្រុមដែលតំណាងឲ្យផលប្រយោជន៍របស់ស្ត្រី យុវវ័យ និងក្រុមជនងាយរងគ្រោះនានាក្នុងការចូលរួមពង្រឹងការចាត់ចែង ការប្រើប្រាស់ថវិកា និងការផ្ដល់សេវាសាធារណៈនៅមូលដ្ឋាន តាមរយៈការលើកកម្ពស់នូវភាពងាយស្រួលទទួលបានព័ត៌មាន និងការចូលរួមពិនិត្យតាមដានលើការងារថវិកា និង ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

- **គណនេយ្យភាពផ្នែកច្បាប់** ៖ សំដៅទៅលើគណនេយ្យភាព

ចំពោះមុខច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន។

- ...។ល។

# ២. ក្របខ័ណ្ឌច្បាប់សម្រាប់ការអនុវត្ត គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ

រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមឲមានការសិក្សា ពិចារណាអំពីការកែទម្រង់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ ចាប់ពីឆ្នាំ ១៩៩៩ ក្រោមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រត្រីកោណរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី២នៃរដ្ឋសភា។ គំនិតផ្តួចផ្តើមនេះ បានបន្តអនុវត្តនៅក្នុងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងទី៣របស់រាជរដ្ឋាភិបាលបន្តទៀត។

ដោយផ្អែកលើឆន្ទៈ និងការប្តេជ្ញាចិត្តនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌច្បាប់មួយចំនួន សម្រាប់គាំទ្រការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ពិសេសសម្រាប់ធានាឲមានគណនេយ្យភាពតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ក្របខ័ណ្ឌច្បាប់ទាំងនោះមានដូចជា ៖

- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- លិខិតបទដ្ឋានគតិយុត្តនានា

## ២.១. ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ដើម្បីពង្រឹងការអនុវត្តគណនេយ្យភាពនៅថ្នាក់ក្រោមជាតិ និងបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ តាមរយៈក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌយុទ្ធសាស្ត្រសំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

- ការបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈ នៅថ្នាក់ក្រោមជាតិ តម្រូវឱ្យ**<u>បង្កើតនូវយន្តការមួយ</u>** ដែលត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- **<u>បង្កើតស្ថាប័ន</u>**នៅថ្នាក់ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដែលមានតំណាងជាប់ឆ្នោត ដើម្បីជួយលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋ សំដៅលើកកម្ពស់ការឆ្លើយតបចំពោះតម្រូវការនៅមូលដ្ឋាន និងអនុ-ញ្ញាតឱ្យមូលដ្ឋានធ្វើការសម្រេចចិត្ត ប្រកាន់យកជម្រើសនានាទាក់ទងនឹងការអភិវឌ្ឍមូលដ្ឋាន ដែលមានគណនេយ្យភាពលើការធ្វើសេចក្តី-សម្រេច និងសកម្មភាពរបស់ខ្លួន។
- នៅថ្នាក់រដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបង្កើតឱ្យមាន**<u>ក្រុមប្រឹក្សា</u>**មួយ តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ដើម្បីធានាដល់កិច្ចដំណើរការការងាររបស់ថ្នាក់រដ្ឋបាលទាំងនោះ ប្រកបដោយតម្លា-ភាព និងគណនេយ្យភាព។

ដូច្នេះ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ គឺជាអង្គ



បណ្ណាល័យ
គ.ជ.អ.ប

ដែលកើតចេញពីការបោះឆ្នោត ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ដែលនៅកៀកប្រជាពលរដ្ឋ និងដែលមានតួនាទីចម្បងក្នុងការធានាឱ្យមានប្រសិទ្ធភាពខ្ពស់បំផុតនៃការផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ព្រមទាំងត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ២.២. ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ក្នុងមាត្រា៤១បានចង្អុលបង្ហាញឱ្យរដ្ឋបាលឃុំ សង្កាត់ដែលគ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីក្នុងការជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលមានប្រកបដោយចីរភាពសម្រាប់បំពេញសេចក្ដីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។ តាមន័យនេះ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធានាឱ្យមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋអំពីការធ្វើសេចក្ដីសម្រេចចិត្ត និងអនុវត្តសេចក្ដីសម្រេចចិត្តរបស់ខ្លួន ស្របតាមគោលការណ៍អភិបាលកិច្ចល្អដែលបានកំណត់។

## ២.៣. ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ដើម្បីធានាដល់ការអនុវត្តគណនេយ្យភាពតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ច្បាប់ស្ដីពីការគ្រង់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង

ស្រុក ខណ្ឌបានកំណត់អំពីការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដូចខាងក្រោម ៖

- ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាព ដើម្បីធ្វើសេចក្តីសម្រេច ធានាបាននូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដូច្នេះក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណា ដែលខ្លួនយល់ឃើញថា មានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាង ព្រមទាំងអាចផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះ និងត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាល និងអភិបាល (មាត្រា ៣៤)។
- ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យសកម្មភាព និងការអនុវត្តរបស់គណៈអភិ-បាល និងអភិបាល។ ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចកោះអញ្ជើញគណៈអភិបាល ឬអភិបាល និងបុគ្គល ដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សា (មាត្រា១៥៧)។
- ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិ-បត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា (មាត្រា៣៥)។

## ២.៤. លិខិតបទដ្ឋានគតិយុត្តនានា

យោងតាមអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានី ក្រុមប្រឹក្សា គណៈអភិបាលខណ្ឌ និងអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និង

ទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង ក្រុមប្រឹក្សា គណៈអភិបាលស្រុកបានកំណត់កាន់តែលម្អិតអំពីការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ខ្លឹមសារសំខាន់ៗទាំងនោះ មានដូចជា ៖

ក). សម្រាប់រដ្ឋបាលរាជធានី រដ្ឋបាលខណ្ឌ រដ្ឋបាលសង្កាត់

- ក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវធ្វើប្រតិភូកម្មមុខងារ និងភារកិច្ចឱ្យបានសមស្របដល់ក្រុមប្រឹក្សាខណ្ឌ ដើម្បីក្រុមប្រឹក្សាខណ្ឌនីមួយៗលើកកម្ពស់ការចូលរួម និងភាពជាម្ចាស់របស់ប្រជាពលរដ្ឋសំដៅបង្កើតជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមខណ្ឌនីមួយៗ (មាត្រា៦៥នៃអនុក្រឹត្យលេខ២១៥)។
- ក្រុមប្រឹក្សាខណ្ឌនីមួយៗ ដែលបានទទួលការធ្វើប្រតិភូកម្មមុខងារភារកិច្ចពីក្រុមប្រឹក្សារាជធានីភ្នំពេញ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ និងចំពោះក្រុមប្រឹក្សាសង្កាត់នានាក្នុងខណ្ឌរបស់ខ្លួន និងត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារាជធានីភ្នំពេញ អំពីភាពត្រឹមត្រូវតាមច្បាប់នៃការអនុវត្តមុខងារ ភារកិច្ចដែលខ្លួនបានទទួលការធ្វើប្រតិភូកម្មទាំងនោះ (មាត្រា៦៧ នៃអនុក្រឹត្យលេខ២១៥)។
- ក្រុមប្រឹក្សាសង្កាត់ត្រូវទទួលខុសត្រូវក្នុងការផ្តល់យោបល់ និងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខណ្ឌ ដើម្បីធានាថា ក្រុមប្រឹក្សារាជធានី និងក្រុមប្រឹក្សាខណ្ឌនៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងមានគណនេយ្យភាពចំពោះ

ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (មាត្រា១១៦នៃអនុក្រឹត្យលេខ២១៥)។

ខ). រដ្ឋបាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់

- ក្រុមប្រឹក្សាខេត្តត្រូវសហការជាមួយក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកក្នុងខេត្តរបស់ខ្លួន ដើម្បីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងខេត្តរបស់ខ្លួន ក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ (មាត្រា១៨៥នៃអនុក្រឹត្យលេខ២១៦)។
- ដើម្បីលើកកម្ពស់គណនេយ្យភាពរបស់ក្រុមប្រឹក្សាស្រុកចំពោះប្រជាពលរដ្ឋរបស់ខ្លួន ក្រុមប្រឹក្សាស្រុកត្រូវរៀបចំឱ្យមាន**<u>យន្តការពិគ្រោះពិភាក្សា</u>**ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក សំដៅធានាឱ្យបានថា ជម្រើសសេចក្តីសម្រេច និងសកម្មភាពរបស់ក្រុមប្រឹក្សាស្រុកមានការឆ្លើយតបចំពោះតម្រូវការជាអាទិភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក និងប្រជាពលរដ្ឋទាំងអស់ក្នុងស្រុករបស់ខ្លួន (មាត្រា១១៦នៃអនុក្រឹត្យលេខ២១៦)។
- ក្រុមប្រឹក្សាស្រុកអាចធ្វើការពិគ្រោះយោបល់ និងសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ដើម្បីប្រើប្រាស់នូវបុគ្គលិករបស់រដ្ឋបាលស្រុក ដើម្បីជួយគាំទ្រធនធានផ្នែករដ្ឋបាល និងផ្នែកសមត្ថភាពដល់រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់តាមការចាំបាច់។ បុគ្គលិករបស់ស្រុកដែលចាត់ឱ្យជួយគាំទ្រខាងលើនេះ ត្រូវមានគណនេយ្យភាព

អំពីសកម្មភាពរបស់ខ្លួនចំពោះក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ដែលខ្លួនគាំទ្រ ហើយត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុកអំពីការគោរព និងការអនុវត្តភារកិច្ចស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា (មាត្រា១២៤នៃអនុក្រឹត្យលេខ២១៦)។

- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្តល់យោបល់ ពិគ្រោះយោបល់ និងត្រួតពិនិត្យ ដើម្បីធានាថាក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុកនៅតែឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន និងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់ក្នុងខេត្ត (មាត្រា១៨៥នៃអនុក្រឹត្យលេខ២១៦)។
- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង និងក្រុមប្រឹក្សាស្រុកអំពីតម្រូវការនានារបស់ប្រជាពលរដ្ឋដែលក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់មិនអាចដោះស្រាយបានដោយសមត្ថភាព និងធនធានដែលខ្លួនមាន (មាត្រា១៨៥នៃអនុក្រឹត្យលេខ២១៦)។
- ក្រុមប្រឹក្សាស្រុក ត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុក អំពីជម្រើស សេចក្តីសម្រេច ការអនុវត្តរបស់ខ្លួន ព្រមទាំងផលប៉ះពាល់នៃជម្រើស សេចក្តីសម្រេច និងការអនុវត្តទាំងនោះ (មាត្រា១៨៤នៃអនុក្រឹត្យលេខ២១៦)។

ក្រៅពីលិខិតបទដ្ឋានគតិយុត្តខាងលើ ក៏នៅមានឯកសារគោលនយោបាយ និងឯកសារកម្មវិធីផ្សេងៗទៀតបានកំណត់អំពីការអនុវត្តគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ ដូចជា ផែនការយុទ្ធសាស្ត្រស្តីពី

ការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ឯកសារកម្មវិធីជាតិ និងឯកសារផអ៣ដំណាក់កាលទី១ និងទី២ជាដើម។

# ៣. ការអនុវត្តគណនេយ្យភាព របស់រដ្ឋបាលថ្នាក់ក្រោមជាតិ

ក្នុងការឆ្លើយតបទៅនឹងឆន្ទៈ និងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា អំពីការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវពង្រឹងការអនុវត្តគណនេយ្យភាពរបស់ខ្លួន។ ដូច្នេះ ដើម្បីធានាឲមានការអនុវត្តគណនេយ្យភាពនៅក្នុងរដ្ឋបាលរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវពង្រឹង ៖

- គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ
- គណនេយ្យភាពផ្ទៃក្នុង
- គណនេយ្យភាពរបស់រដ្ឋបាល (អ្នកផ្តល់សេវា) ចំពោះប្រជាពលរដ្ឋ
- គណនេយ្យភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិចំពោះរាជរដ្ឋាភិបាល

## ៣.១. គណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះ ប្រជាពលរដ្ឋ

ដើម្បីធានាឲមានគណនេយ្យភាពរបស់ក្រុមប្រឹក្សាចំពោះប្រជាពលរដ្ឋ ឬគណនេយ្យភាពតាមបែបប្រជាធិបតេយ្យ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវរៀបចំយន្តការ និងមធ្យោបាយសមស្របនានាក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងការអនុវត្តសេចក្តីសម្រេចចិត្តរបស់ខ្លួនប្រកបដោយតម្លាភាព ការពិគ្រោះយោបល់ និងការទទួលបានព័ត៌មានគ្រប់គ្រាន់

ព្រមទាំងទទួលបាននូវព័ត៌មាន ឬពាក្យបណ្ដឹង ត្រឡប់ពីប្រជាពលរដ្ឋដែលរងផលប៉ះពាល់ពីសេចក្ដីសម្រេចរបស់ខ្លួន។

ដូច្នេះ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗគប្បីពិចារណាលើចំណុចសំខាន់ៗមួយចំនួនដូចខាងក្រោម ៖

### ៣.១.១. ការប្រមូលបញ្ហា តម្រូវការ និងមតិយោបល់

ដើម្បីឲក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចដឹងអំពីបញ្ហា តម្រូវការ ការបារម្ភ និងមតិយោបល់ ឬសំឡេងរបស់ប្រជាពលរដ្ឋដែលត្រូវបានយកចិត្តទុកដាក់ ក្រុមប្រឹក្សាត្រូវបង្កើតឱ្យមានយន្តការ ឬវិធីសាស្ត្រនានាសម្រាប់ការប្រាស្រ័យទាក់ទងជាទៀងទាត់រវាងមន្ត្រី បុគ្គលិកនៃរដ្ឋបាលថ្នាក់ក្រោមជាតិជាមួយប្រជាពលរដ្ឋ សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀត។

យន្តការ ឬ វិធីសាស្ត្រមួយចំនួន សម្រាប់ប្រមូលបាននូវបញ្ហា តម្រូវការ និងមតិយោបល់ ឬសំឡេងរបស់ប្រជាពលរដ្ឋ អាចមានដូចជា ៖

- **ការផ្សព្វផ្សាយព័ត៌មាន** ៖ ក្រុមប្រឹក្សាត្រូវចាត់ចែងឲរដ្ឋបាលរបស់ខ្លួនធ្វើការផ្សព្វផ្សាយអំពីសារៈសំខាន់នៃការចូលរួមរបស់ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធនានាក្នុងដំណើរការនៃការធ្វើសេចក្ដីសម្រេច និងអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា។ ជាមួយគ្នានេះ ក្រុមប្រឹក្សាក៏ត្រូវធ្វើការផ្សព្វផ្សាយជាលាយលក្ខណ៍អក្សរ អំពីតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សា គណៈអភិបាល នាយករដ្ឋបាល និងគណៈ-កម្មាធិការនានារបស់ក្រុមប្រឹក្សា និងអង្គភាពនានានៃរដ្ឋបាលថ្នាក់ក្រោមជាតិជូនសាធារណជនផងដែរ។ ក្រៅពីនេះ ក្រុមប្រឹក្សាក៏ត្រូវធានាផងដែរថា រាល់ព័ត៌មាននានាពាក់ព័ន្ធនឹងការអនុវត្តការងារ

របស់រដ្ឋបាលខ្លួនត្រូវបានផ្សព្វផ្សាយជាសាធារណៈ (លើកលែងតែ ព័ត៌មានមួយចំនួនដែលត្រូវហាមឃាត់ការផ្សព្វផ្សាយជាសាធារណៈ)។

- **ការរៀបចំកិច្ចប្រជុំ ៖** រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើងជាសាធារណៈ និងមានការចូលរួមពីប្រជាពលរដ្ឋទាំងបុរស ស្ត្រី និងក្រុមជនងាយរងគ្រោះ ក្រុមប្រឹក្សាប្រភេទដូចគ្នា ក្រុមប្រឹក្សាប្រភេទផ្សេងគ្នា មន្ទីរ អង្គភាព ការិយាល័យ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធផ្សេងទៀត។ ដើម្បីធានាឱមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធក្នុងកិច្ចប្រជុំ ក្រុមប្រឹក្សាត្រូវធានាថា ៖
  - ប្រតិទិនប្រចាំឆ្នាំនៃការប្រជុំរបស់ក្រុមប្រឹក្សាត្រូវបានផ្សព្វផ្សាយជាសាធារណៈ
  - កម្មវិធីប្រជុំជាក់លាក់នីមួយៗរបស់ក្រុមប្រឹក្សាត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដោយបញ្ជាក់យ៉ាងច្បាស់លាស់អំពីពេលវេលា ទីកន្លែង និងសេចក្តីព្រាងរបៀបវារៈជាដើម
  - ទីកន្លែងប្រជុំបានបង្កលក្ខណៈងាយស្រួលដល់អ្នកចូលរួមក្នុងការសង្កេត និងបញ្ចេញមតិយោបល់
  - ក្រៅពីផ្សព្វផ្សាយឱមានការចូលរួមពីសាធារណជនទូទៅ លិខិតអញ្ជើញចូលរួមកិច្ចប្រជុំត្រូវបានរៀបចំសម្រាប់ក្រុម ឬបុគ្គលជាក់លាក់ដែលត្រូវអញ្ជើញឱចូលរួមពិភាក្សា ផ្តល់យោបល់លើប្រធានបទជាក់លាក់ (តាមសេចក្តីព្រាងរបៀបវារៈ) និងត្រូវធានាផងដែរថា លិខិតអញ្ជើញនោះបានបញ្ជូនដល់អ្នកទាំងនោះស្របតាម

បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។ល។

**បញ្ជាក់** ៖ នីតិវិធីលម្អិតសម្រាប់ការរៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា សូមមើលនៅក្នុងឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំក្រុមប្រឹក្សាសម្រាប់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

- **ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់** ៖ ក្រុមប្រឹក្សាត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ប្រចាំឆ្នាំរបស់ខ្លួន ដែលតាមរយៈវេទិកានេះ ក្រុមប្រឹក្សាអាចជម្រាបអំពីសកម្មភាព និងលទ្ធផលសម្រេចបានក្នុងឆ្នាំកន្លងទៅ និងបង្ហាញអំពីផែនការសកម្មភាពសម្រាប់ឆ្នាំបន្ទាប់ដើម្បីពិភាក្សាជាមួយប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធទាំងអស់។ លើសពីនេះទៀត វេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នេះ ផ្តល់ឱកាសឲរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីធ្វើការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកជាមួយប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល វិស័យឯកជន ព្រមទាំងទទួលយកនូវសំណើ សំណូមពរ ការព្រួយបារម្ភ បំណងប្រាថ្នានានា ដែលជាតម្រូវការរបស់ពួកគេ ដើម្បីធ្វើការដោះស្រាយ និងឆ្លើយតប។ ដើម្បីធានាថា ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ត្រូវបានរៀបចំឡើង និងទទួលបានលទ្ធផលល្អ ក្រុមប្រឹក្សាត្រូវធានាថា ៖
  - ព័ត៌មានពាក់ព័ន្ធនឹងការរៀបចំវេទិកានេះត្រូវបានផ្សព្វផ្សាយជាសាធារណៈតាមមធ្យោបាយផ្សព្វផ្សាយនានាដែលប្រជាពលរដ្ឋអាចទទួលបាននូវព័ត៌មានទាំងនោះដោយងាយស្រួល

- ប្រជាពលរដ្ឋ (បុរស ស្ត្រី កុមារា កុមារី ជនងាយរងគ្រោះ...) ក្រុមប្រឹក្សាពាក់ព័ន្ធ អង្គការសង្គមស៊ីវិល និងអ្នកពាក់ព័ន្ធទាំង-អស់ត្រូវបានអញ្ជើញឱ្យចូលរួម
- ប្រជាពលរដ្ឋ និងអ្នកចូលរួមទាំងអស់មានឱកាសគ្រប់គ្រាន់ក្នុងការបញ្ចេញមតិយោបល់របស់ខ្លួន
- រាល់សំណើ សំណូមពរ និងយោបល់ទាំងអស់ត្រូវបានកត់ត្រា និងលើកយកមកពិភាក្សាក្នុងកិច្ចប្រជុំបន្ទាប់របស់ក្រុមប្រឹក្សា ដើម្បីចាត់វិធានការដោះស្រាយ និងឆ្លើយតបតាមរយៈការដោះស្រាយ

  ឬតាមរយៈការបកស្រាយប្រកបដោយភាពសមហេតុផល និងអាចទទួលយកបាន។

**<u>បញ្ជាក់ :</u>** នីតិវិធីលម្អិតសម្រាប់ការរៀបចំវេទិកានេះ សូមមើលនៅក្នុងឯកសារបច្ចេកទេសស្តីពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់សម្រាប់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

- **ការរៀបចំវេទិកាដទៃទៀត** ៖ ក្រៅពីរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ប្រចាំឆ្នាំខាងលើ ក្រុមប្រឹក្សាអាចរៀបចំវេទិកាផ្សេងៗទៀតសម្រាប់ពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដូចជា វេទិកាពិគ្រោះយោបល់អំពីការរៀបចំផែនការអភិវឌ្ឍន៍ វេទិកាអំពីការរៀបចំដីកា វេទិកាទាក់ទងនឹងការប្រើប្រាស់ថវិកាជាដើម។ តាមរយៈវេទិកា

ទាំងនេះ ក្រុមប្រឹក្សា ឬបុគ្គលិកក្រុមប្រឹក្សាអាចស្តាប់អំពីបញ្ហា តម្រូវការ និងសំណូមពររបស់ប្រជាពលរដ្ឋរបស់ខ្លួន ហើយក៏ជាវេទិកាសម្រាប់ក្រុមប្រឹក្សា ឬបុគ្គលិករបស់ក្រុមប្រឹក្សាក្នុងការឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនផងដែរ។

- **ការរៀបចំយន្តការសម្រាប់ទទួល និងផ្តល់ព័ត៌មាន** ៖ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ គួររៀបចំឲមានយន្តការជាក់លាក់សម្រាប់ទទួល និងផ្តល់ព័ត៌មាននៅរដ្ឋបាលរបស់ខ្លួន ដូចជា ៖
  - **នៅថ្នាក់រាជធានី ខេត្ត** ៖ រាជធានី ខេត្តមានក្រុមមន្ត្រីទទួលបន្ទុកព័ត៌មានរបស់រដ្ឋបាលរាជធានី ខេត្ត។ ក្រុមមន្ត្រីទទួលបន្ទុកព័ត៌មាននេះមានតួនាទីជាអ្នកនាំពាក្យ និងជាមន្ត្រីទំនាក់ទំនងសាធារណៈរបស់រដ្ឋបាលរាជធានី ខេត្ត។
  - **នៅថ្នាក់ក្រុង ស្រុក ខណ្ឌ** ៖ ក្រុង ស្រុក ខណ្ឌគួរពង្រឹងការអនុវត្តតួនាទីរបស់ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុក្នុងការអនុវត្តការងារផ្សព្វផ្សាយ និងទទួលព័ត៌មានពីសាធារណជននៅក្នុង ក្រុង ស្រុក ខណ្ឌរបស់ខ្លួន។ ដោយឡែកចំពោះ ក្រុង ស្រុក ខណ្ឌ ដែលមានការិយាល័យច្រកចេញចូលតែមួយ ត្រូវពង្រឹងការអនុវត្តយន្តការដែលបានបង្កើត ដូចជា ពង្រឹងការអនុវត្តម៉ោងជួបប្រជាពលរដ្ឋ ការរៀបចំវេទិកាពិគ្រោះយោបល់សាធារណៈប្រចាំឆមាស ការរៀបចំយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន និងការរៀបចំវេទិកាប្រជាពលរដ្ឋប្រចាំឆ្នាំជាដើម។
  - **នៅថ្នាក់ឃុំ សង្កាត់** ៖ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពង្រឹងការអនុវត្ត

តួនាទី ភារកិច្ចរបស់មេភូមិតាមភូមិនីមួយៗនៃឃុំ សង្កាត់ដើម្បី បម្រើការងារជាអ្នកទំនាក់ទំនងរវាងក្រុមប្រឹក្សាជាមួយនឹងប្រជាពលរដ្ឋ។ ក្រៅពីមេភូមិ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវពង្រឹងគណៈកម្មាធិការនានាដែលបានបង្កើតឡើង ពិសេស គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ ដែលគណៈកម្មាធិការនេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការដោះស្រាយបញ្ហាដែលពាក់ព័ន្ធនឹងនារី និងកុមារក្នុងឃុំ សង្កាត់។

**<u>កំណត់សម្គាល់</u>** ៖ ផ្អែកតាមបទពិសោធន៍នៃការអនុវត្តម៉ោងជួបប្រជាពលរដ្ឋរបស់ការិយាល័យច្រកចេញចូលតែមួយ ដើម្បីពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ រដ្ឋបាលរាជធានី រដ្ឋ-បាលខេត្ត រដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ (ក្រៅពីក្រុង ស្រុក ខណ្ឌដែលមានការិយាល័យច្រកចេញចូលតែមួយ) គួររៀបចំឱ្យមានកាលវិភាគសម្រាប់ម៉ោងជួបប្រជាពលរដ្ឋ ដោយកំណត់យកថ្ងៃណាមួយនៃសប្តាហ៍ ដូចជា រៀងរាល់ថ្ងៃច័ន្ទជាដើម។

- **ការរៀបចំបញ្ជីឈ្មោះទំនាក់ទំនង** ៖ ក្រុមប្រឹក្សាត្រូវចាត់ឱ្យនាយករដ្ឋបាលរបស់ខ្លួនក្នុងការរៀបចំបញ្ជីឈ្មោះសម្រាប់ឱ្យប្រជាពលរដ្ឋ អាចទំនាក់ទំនងដោយផ្ទាល់មករដ្ឋបាលរបស់ខ្លួន។ បញ្ជីឈ្មោះទំនាក់ទំនងនេះ គួរបញ្ចូលនូវឈ្មោះ មុខតំណែង លេខទូរស័ព្ទ (ដូចមានក្នុងតារាងបញ្ជីគំរូ)។ សមាសភាពដែលគួរបញ្ចូលក្នុងបញ្ជីនេះ រួមមាន ៖

- ប្រធានក្រុមប្រឹក្សា
- គ្រប់សមាជិកក្រុមប្រឹក្សា
- អភិបាល
- អភិបាលរង
- នាយករដ្ឋបាល
- នាយករងរដ្ឋបាល និង
- បុគ្គលិកផ្សេងទៀតតាមការចាំបាច់

បន្ទាប់ពីរៀបចំបញ្ជីនេះរួច នាយករដ្ឋបាលត្រូវចាត់ចែងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់អ្នកពាក់ព័ន្ធទាំងអស់ និងត្រូវបិទផ្សាយជាប្រចាំនៅលើក្តារព័ត៌មាននៅមុខសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌរបស់ខ្លួន (តារាងគំរូទី១)។

- **ការពង្រឹងការប្រើប្រាស់ប្រអប់សំបុត្រគណនេយ្យភាព ៖** ប្រអប់សំបុត្រគណនេយ្យភាព បានដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលព័ត៌មានអំពីបញ្ហាប្រឈមនានាក្នុងការអនុវត្តមូលនិធិឃុំ សង្កាត់។ នាពេលខាងមុខដ៏ខ្លី ប្រអប់សំបុត្រគណនេយ្យភាពនេះ អាចនឹងជួយប្រមូលព័ត៌មានពាក់ព័ន្ធនឹងការអនុវត្តមូលនិធិក្រុង ស្រុក និងការអនុវត្តថវិការបស់រាជធានី ខេត្តផងដែរ។ ប្រអប់សំបុត្រគណនេយ្យភាព គឺជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងអំពីការអនុវត្តរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ តាមរយៈប្រអប់សំបុត្រគណនេយ្យភាព រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចដឹងអំពីបញ្ហា តម្រូវការ និងការមិនពេញចិត្តនានារបស់ប្រជាពលរដ្ឋ។ ដូច្នេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗនោះអាចធ្វើការកែលម្អនូវការអនុវត្តរបស់ខ្លួន ឬអាចចាត់

វិធានការដោះស្រាយ និង ឬអាចឆ្លើយតបចំពោះប្រជាពលរដ្ឋបាន ប្រកបដោយប្រសិទ្ធភាព។

- **ការទទួលយកការតវ៉ារបស់ប្រជាពលរដ្ឋ ឬក្រុមប្រជាពលរដ្ឋ** ៖ ការប្តឹងតវ៉ារបស់ប្រជាពលរដ្ឋ ឬក្រុមប្រជាពលរដ្ឋ គឺជាកញ្ចក់សម្រាប់ឆ្លុះបញ្ចាំងអំពីការអនុវត្តរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។ ប្រសិនបើការសម្រេចចិត្តរបស់ក្រុមប្រឹក្សាផ្តល់ផលជាវិជ្ជមានដល់ប្រជាពលរដ្ឋ នោះប្រជាពលរដ្ឋនឹងមិនធ្វើការតវ៉ាឡើយ។ ប៉ុន្តែប្រសិនបើការសម្រេច និងការអនុវត្តសេចក្តីសម្រេចចិត្តណា ដែលផ្តល់ផលប៉ះពាល់ជាអវិជ្ជ-មានដល់ពួកគាត់ នោះប្រជាពលរដ្ឋដែលរងផលប៉ះពាល់ទាំងនេះនឹងធ្វើការតវ៉ា។ ដូច្នេះក្រុមប្រឹក្សា គណៈអភិបាលត្រូវស្វាគមន៍ចំពោះការតវ៉ាទាំងនោះ ហើយត្រូវពិចារណាដោះស្រាយ ឬឆ្លើយតបទៅប្រជាពល-រដ្ឋវិញប្រកបដោយភាពសមហេតុផល និងអាចទទួលយកបានពីសំណាក់អ្នកទទួលផលប៉ះពាល់ទាំងនោះ។
- ផ្តល់ការអនុញ្ញាតឱ្យប្រជាពលរដ្ឋ អាចពិនិត្យឯកសារសំខាន់ៗរបស់ក្រុមប្រឹក្សានៅការិយាល័យនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចស្នើសុំថតចម្លងឯកសារនានារបស់ក្រុមប្រឹក្សាបាន (លើកលែងឯកសារសម្ងាត់ ឬឯកសារដែលច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តបានកំណត់អំពីកម្រិតនៃការផ្សព្វផ្សាយជាសាធារណៈ)។
- ដាក់បញ្ចូល និងតែងតាំងតំណាងប្រជាពលរដ្ឋ ឬតំណាងអង្គការសង្គមស៊ីវិលជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មការ ឬក្រុមការងារចំពោះកិច្ចនានា ដោយផ្តល់នូវតួនាទីសមស្រប មិនមែនត្រឹមតែជាអ្នក

សង្កេតការណ៍ ឬអ្នកប្រឹក្សាយោបល់ឡើយ។

- រៀបចំយន្តការផ្សេងៗទៀតតាមការចាំបាច់ ដើម្បីធានាថា ប្រជាពលរដ្ឋទាំងបុរស ស្ត្រី និងក្រុមជនងាយរងគ្រោះមានឱកាសក្នុងការបញ្ចេញមតិយោបល់លើកឡើងអំពីបញ្ហា តម្រូវការ ការតវ៉ារបស់ខ្លួន ហើយក្រុមប្រឹក្សាអាចដឹង និងកត់ត្រានូវរាល់បញ្ហា តម្រូវការរបស់ប្រជាពលរដ្ឋ ព្រមទាំងបានពិចារណា និងចាត់វិធានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព។

**គំរូទី ១**

**បញ្ជីឈ្មោះទំនាក់ទំនង**

**រដ្ឋបាល**..................................

| ល.រ | ឈ្មោះ | ភេទ | មុខតំណែង | លេខទូរស័ព្ទ |
|---|---|---|---|---|
| ១ | | | | |
| ២ | | | | |
| ៣ | | | | |
| ៤ | | | | |
| ៥ | | | | |
| ៦ | | | | |
| ៧ | | | | |
| ៨ | | | | |
| ... | | | | |

## ៣.១.២). ការឆ្លើយតប

បន្ទាប់ពីទទួលបានព័ត៌មាន សំណួរ ការស្នើសុំការបំភ្លឺ ឬការបារម្ភរបស់ប្រជាពលរដ្ឋ ក្រុមប្រឹក្សា និងគណៈអភិបាលត្រូវចាត់ចែងធ្វើការឆ្លើយ

តបឲបានយ៉ាងលឿនបំផុតតាមដែលអាចធ្វើបាន។ ការឆ្លើយតបអាចធ្វើតាមរយៈ ៖

- ការស្រាយបំភ្លឺ ការឆ្លើយ ឬការបញ្ជាក់អំពីមូលហេតុនៃការសម្រេចចិត្ត និងការអនុវត្តសេចក្ដីសម្រេចចិត្តនោះ ប្រកបដោយភាពសមហេតុផល និងអាចទទួលយកបានពីសំណាក់ប្រជាពលរដ្ឋ និងអ្នករងផលប៉ះពាល់។ ជាការប្រសើរការស្រាយបំភ្លឺគួរធ្វើឡើងយ៉ាងយូរក្នុងរយៈពេល០១សប្ដាហ៍បន្ទាប់ពីទទួលបានព័ត៌មាន។ ការស្រាយបំភ្លឺ ឬការឆ្លើយតបរបៀបនេះអាចធ្វើឡើងដោយផ្ទាល់មាត់ ឬដោយលាយ លក្ខណ៍អក្សរ ៖
  - **ការឆ្លើយតបដោយផ្ទាល់មាត់** ៖ អាចធ្វើឡើងតាមរយៈការជួបដោយផ្ទាល់ជាមួយអ្នកស្នើសុំ ឬតាមរយៈការប្រកាសផ្សព្វផ្សាយតាមមធ្យោបាយនានាដូចជា ឧគ្ឃោសនស័ព្ទ ឬវិទ្យុ និងឬតាមមធ្យោបាយសមស្របផ្សេងៗទៀត។
  - **ការឆ្លើយតបជាលាយលក្ខណ៍អក្សរ** ៖ អាចធ្វើឡើងតាមរយៈលិខិត ឬសារព័ត៌មាន សម្រាប់ឆ្លើយតបចំពោះបុគ្គល ឬក្រុមអ្នកស្នើសុំ។
- ការដោះស្រាយ ឬការចាត់វិធានការ ឬការអនុវត្តសកម្មភាពណាមួយដែលចូលរួមចំណែកក្នុងការឆ្លើយតបនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ ជាការប្រសើរ ការឆ្លើយតបតាមរយៈការដោះស្រាយត្រូវធ្វើឡើងមិនគួរលើសរយៈពេល៣០ថ្ងៃ បន្ទាប់ពីទទួលបានបញ្ហា តម្រូវការ និងឬមតិយោបល់ពីប្រជាពលរដ្ឋ។

**ឧទាហរណ៍ ៖**

- ប្រជាពលរដ្ឋស្នើសុំឲក្រុមប្រឹក្សាស្រុកជួយដោះស្រាយបញ្ហាគ្មានអនាម័យនៅក្នុងផ្សារក្នុងទីរួមស្រុករបស់ខ្លួន។ បន្ទាប់ពីទទួលបានការស្នើសុំនេះ ក្រុមប្រឹក្សាត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ដើម្បីពិនិត្យ និងសម្រេចអំពីដំណោះស្រាយបញ្ហានេះ និងណែនាំឲអភិបាលចាត់ចែងអនុវត្តសេចក្តីសម្រេចនេះប្រកបដោយប្រសិទ្ធភាព។ ចំណាត់ការរបស់ក្រុមប្រឹក្សានេះ គឺជាការអនុវត្តគណនេយ្យភាពចំពោះប្រជាពលរដ្ឋតាមរយៈការដោះស្រាយនូវបញ្ហារបស់ប្រជាពលរដ្ឋ។

<u>**បទពិសោធន៍**</u> ៖ អភិបាលរងខណ្ឌ០១រូបបានមានប្រសាសន៍ថា ការតវ៉ារបស់ប្រជាពលរដ្ឋមិនមែនជារឿងអាក្រក់ទាំងអស់នោះទេ។ ជាការពិតនៅពេលប្រជាពលរដ្ឋមិនពេញចិត្តនឹងអ្វីដែលរដ្ឋបាលខណ្ឌបានធ្វើ នោះពួកគាត់នឹងធ្វើការតវ៉ា។ ដូច្នេះរដ្ឋបាលខណ្ឌចាំបាច់ត្រូវពិនិត្យមើលលើបញ្ហាដែលប្រជាពលរដ្ឋបានលើកឡើងដោយត្រូវសិក្សា ស្រាវជ្រាវឲបានច្បាស់លាស់ ហើយត្រូវឆ្លើយតបទៅប្រជាពលរដ្ឋវិញឲបានលឿនតាមដែលអាចធ្វើបាន។ រាល់ការឆ្លើយតបត្រូវតែមានហេតុផលត្រឹមត្រូវ សមហេតុផល និងអាចទទួលយកបានពីសំណាក់ប្រជាពលរដ្ឋដែលបានមកតវ៉ានោះ។

## ៣.២. គណនេយ្យភាពផ្ទៃក្នុង

គណេយ្យភាពផ្ទៃក្នុង សំដៅលើគណនេយ្យភាពនៅក្នុងអង្គការ

ចាត់តាំងមួយនៃរដ្ឋបាលថ្នាក់ក្រោមជាតិតាមឋានានុក្រមនៃរចនាសម្ព័ន្ធរបស់រដ្ឋបាលនីមួយៗនោះ។

គណនេយ្យភាពផ្ទៃក្នុងនៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចមានដូចជា ៖

- គណនេយ្យភាពរបស់គណៈអភិបាលចំពោះក្រុមប្រឹក្សា
- គណនេយ្យភាពរបស់គណៈកម្មាធិការនានាចំពោះក្រុមប្រឹក្សា
- គណនេយ្យភាពរបស់នាយក នាយករងរដ្ឋបាលចំពោះក្រុមប្រឹក្សា និងគណៈអភិបាល
- គណនេយ្យភាពរបស់ប្រធាន អនុប្រធានអង្គភាពចំពោះនាយករដ្ឋបាល
- គណនេយ្យភាពរបស់ស្មៀនចំពោះមេឃុំ ចៅសង្កាត់

### ៣.២.១. គណនេយ្យភាពរបស់គណៈអភិបាលចំពោះក្រុមប្រឹក្សា

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាលត្រូវផ្តល់យោបល់ជូនក្រុមប្រឹក្សា រាយការណ៍ជូនក្រុមប្រឹក្សា និងជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ ជាមួយគ្នា នេះ គណៈអភិបាលត្រូវជួយក្រុមប្រឹក្សាដើម្បីឱ្យក្រុមប្រឹក្សាសម្រេចបាននូវ ការអនុវត្តមុខងារ សិទ្ធិអំណាច និងភារកិច្ចរបស់ខ្លួន។

ដើម្បីធានាថា គណៈអភិបាលអនុវត្តភារកិច្ចចម្បងៗខាងលើប្រកបដោយប្រសិទ្ធភាព និងមានគណនេយ្យភាពចំពោះក្រុមប្រឹក្សារបស់ខ្លួន គណៈអភិបាលត្រូវ ៖

- រៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់រដ្ឋបាល ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ ក្នុងការរៀបចំផែនការរយៈពេលបីខែនេះ អភិបាលអាចចាត់ឲនាយករដ្ឋបាលរៀបចំដោយបូកសរុបនូវផែនការសកម្មភាពរយៈពេលបីខែរបស់អង្គភាពចំណុះរដ្ឋបាលរបស់ខ្លួន។
- ក្រៅពីផែនការសកម្មភាពរយៈពេលបីខែ ដែលត្រូវដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត គណៈអភិបាលត្រូវរៀបចំផែនការសកម្មភាពប្រចាំខែរបស់រដ្ឋបាល ហើយដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាដើម្បីពិនិត្យ និងផ្តល់យោបល់។ ក្នុងការរៀបចំផែនការសកម្មភាពប្រចាំខែនេះ អភិបាលត្រូវចាត់ឲនាយករដ្ឋបាលបូកសរុបពីផែនការសកម្មភាពរបស់អង្គភាពនានាចំណុះរដ្ឋបាលរបស់ខ្លួន។ ជាមួយគ្នានេះ ក្រុមប្រឹក្សាត្រូវចាត់តាំងសមាជិកក្រុមប្រឹក្សារបស់ខ្លួន ដើម្បីចូលរួមតាមដានការអនុវត្តសកម្មភាពទាំងនោះតាមការចាំបាច់។
- អភិបាលត្រូវចាត់ឲនាយករដ្ឋបាលបញ្ជូនកំណត់ហេតុប្រជុំប្រចាំអឌ្ឍមាស និងប្រចាំខែរបស់ខ្លួនជូនប្រធានក្រុមប្រឹក្សាដើម្បីផ្តល់ជាព័ត៌មាន។ ប្រធានក្រុមប្រឹក្សាត្រូវចាត់ចែងបញ្ជូនកំណត់ហេតុប្រជុំរបស់គណៈអភិបាលទៅសមាជិករបស់ខ្លួនតាមការចាំបាច់។
- គណៈអភិបាលត្រូវរាយការណ៍ជាប្រចាំអំពីសកម្មភាពនៃការអនុវត្ត និងលទ្ធផលនៃការអនុវត្តជូនអង្គប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សា។ របាយការណ៍ដែលត្រូវដាក់ជូនក្រុមប្រឹក្សាដើម្បីពិនិត្យ និងអនុម័តនេះ



បណ្ណាល័យ
គ.ជ.អ.ប

ត្រូវបញ្ជូន និងបែងចែកដល់សមាជិកទាំងអស់របស់ក្រុមប្រឹក្សាឲបាន មុនកិច្ចប្រជុំស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។

- ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាអាចកោះអញ្ជើញគណៈអភិបាល ឬ អភិបាល និងបុគ្គលដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំ សាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សា។ អភិបាល អភិបាលរងត្រូវធ្វើការឆ្លើយតបប្រកបដោយភាពសមហេតុផល និងអាចទទួលយកបានទៅប្រធានក្រុមប្រឹក្សា ឬក្រុមប្រឹក្សា។
- ក្នុងអំឡុងពេលអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សា អភិបាល ឬ អភិបាលរងទទួលបន្ទុក គួរមានការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយ ប្រធានក្រុមប្រឹក្សាតាមការចាំបាច់។

<u>**បទពិសោធន៍**</u> ៖ សមាជិកក្រុមប្រឹក្សាស្រុកមួយរូបមានប្រសាសន៍ថា បច្ចុប្បន្នសេចក្ដីសម្រេចនានាដែលធ្វើឡើងតាមរយៈកិច្ចប្រជុំរបស់ក្រុមប្រឹក្សាមិនទាន់ត្រូវបានអនុវត្តពេញលេញដោយគណៈអភិបាលឡើយ ដោយសារការមិនទាន់យល់ច្បាស់ពីតួនាទីជាបញ្ហាមួយ ប៉ុន្តែសមត្ថភាពក្នុងការបំពេញការងារក្នុងនាមអង្គប្រតិបត្តិជូនក្រុមប្រឹក្សាក៏ជាបញ្ហាសំខាន់ដែរ។ ទន្ទឹមនេះ ឯកឧត្តមប្រធានក្រុមប្រឹក្សាមួយរូបក៏បានលើកយោបល់ថា ដើម្បីពង្រឹងគណនេយ្យភាពរបស់គណៈអភិបាលចំពោះក្រុមប្រឹក្សាឲមានប្រសិទ្ធភាព ចាំបាច់ត្រូវមានការផ្លាស់ប្ដូរឥរិយាបថបុគ្គលជាមុនសិន។

### ៣.២.២. គណនេយ្យភាពរបស់គណៈកម្មាធិការនានា ចំពោះក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវសម្រេចអំពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ អនុគណៈកម្មការ ឬក្រុមការងារនានា។

ដើម្បីធានាឲមានគណនេយ្យភាពរវាងគណៈកម្មាធិការនានា ចំពោះក្រុមប្រឹក្សា គណៈកម្មាធិការនីមួយៗត្រូវ ៖

- **រៀបចំផែនការសកម្មភាព** ៖ គណៈកម្មាធិការនីមួយៗរបស់ក្រុមប្រឹក្សា ត្រូវរៀបចំផែនការសកម្មភាពប្រចាំខែរបស់ខ្លួន ដើម្បីដាក់ជូនក្រុមប្រឹក្សាពិនិត្យ និងផ្ដល់យោបល់។ ដើម្បីធានាថា គណៈកម្មាធិការនីមួយៗ អាចផ្ដល់សេវាពិគ្រោះយោបល់ជូនក្រុមប្រឹក្សាបានប្រកប-ដោយប្រសិទ្ធភាព ក្រុមប្រឹក្សាត្រូវពិនិត្យមើលផែនការសកម្មភាពដែលបានរៀបចំ ហើយត្រូវផ្ដល់យោបល់ ឬស្នើសុំដាក់បញ្ចូលនូវសកម្មភាពនានាដែលក្រុមប្រឹក្សាចង់ឲគណៈកម្មាធិការណាមួយអនុវត្ត។
- **អនុវត្តផែនការសកម្មភាព** ៖ គណៈកម្មាធិការត្រូវអនុវត្តសកម្មភាពរបស់ខ្លួនស្របតាមផែនការដែលបានកំណត់។ ក្នុងការអនុវត្ត គណៈ-កម្មាធិការអាចជួបពិគ្រោះយោបល់ជាមួយប្រធានក្រុមប្រឹក្សា និងគណៈអភិបាលតាមការចាំបាច់។
- **ការរាយការណ៍** ៖ គណៈកម្មាធិការនីមួយៗ ត្រូវរាយការណ៍អំពីសកម្មភាពរបស់ខ្លួនឱ្យបានទៀងទាត់ជូនក្រុមប្រឹក្សា និងគណៈអភិបាលស្របតាមរបៀបរបបការងាររបស់ខ្លួន។ គណៈកម្មាធិការនីមួយៗត្រូវ

ឆ្លើយបំភ្លឺ ឬបកស្រាយអំពីការអនុវត្តផែនការសកម្មភាពរបស់ខ្លួន ឬលទ្ធផលនៃការធ្វើសេចក្ដីសម្រេចរបស់ខ្លួនជូនក្រុមប្រឹក្សា ឬគណៈអភិបាលនៅពេលមានការស្នើសុំ។

## ៣.២.៣. គណនេយ្យភាពរបស់នាយក នាយករងរដ្ឋបាល ចំពោះក្រុមប្រឹក្សា និងគណៈអភិបាល

នាយករដ្ឋបាល មានតួនាទីជាជំនួយការក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។

ដើម្បីធានានូវគណនេយ្យភាពរបស់នាយករដ្ឋបាល ចំពោះក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន នាយករដ្ឋបាលត្រូវ ៖

- **រៀបចំផែនការសកម្មភាព** ៖ នាយករដ្ឋបាលត្រូវរៀបចំផែនការសកម្មភាពរយៈពេលបីខែរបស់រដ្ឋបាល ដើម្បីដាក់ជូនគណៈអភិបាលពិនិត្យ និងផ្ដល់យោបល់ជាមុន មុនពេលអភិបាលដាក់ផែនការសកម្មភាពរយៈពេលបីខែនេះជូនក្រុមប្រឹក្សាពិនិត្យ និងអនុម័ត។ ក្រៅពីផែនការសកម្មភាពរយៈពេលបីខែ នាយករដ្ឋបាលត្រូវរៀបចំផែនការសកម្មភាពប្រចាំខែ ដើម្បីដាក់ជូនគណៈអភិបាលពិនិត្យ និងផ្ដល់យោបល់។
- **អនុវត្តផែនការសកម្មភាព** ៖ នាយករដ្ឋបាលត្រូវចាត់ចែងអនុវត្តសកម្មភាពរបស់ខ្លួនស្របតាមផែនការដែលបានឯកភាព។ ក្នុងការអនុវត្ត នាយករដ្ឋបាលអាចចាត់ចែង និងសម្របសម្រួលជាមួយនាយករងរដ្ឋបាល និងប្រធាន អនុប្រធានអង្គភាពចំណុះ។ ជាមួយគ្នានេះ នាយក

រដ្ឋបាលអាចស្នើសុំការពិគ្រោះយោបល់ និងការណែនាំពីគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួនតាមការចាំបាច់។

- **ការរាយការណ៍** ៖ ក្នុងការអនុវត្តផែនការសកម្មភាពនេះ នាយករដ្ឋ-បាល ត្រូវធ្វើសេចក្តីរាយការណ៍ជូនអភិបាល ឬគណៈអភិបាល ដើម្បីឱអភិបាលមានមូលដ្ឋានគ្រប់គ្រាន់ ក្នុងការធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួន។ នាយករដ្ឋបាលត្រូវឆ្លើយបំភ្លឺ ឬបកស្រាយអំពីការអនុវត្តផែនការសកម្មភាពរបស់ខ្លួន ឬលទ្ធផលនៃការអនុវត្តរបស់ខ្លួនជូនក្រុមប្រឹក្សា ឬគណៈអភិបាលនៅពេលមានការស្នើសុំ។

## ៣.២.៤. គណនេយ្យភាពរបស់ប្រធាន អនុប្រធានអង្គភាព ចំពោះនាយករដ្ឋបាល

យោងតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អង្គភាពរបស់ក្រុមប្រឹក្សានីមួយៗត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់គណៈអភិបាល ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ អង្គភាពនីមួយៗត្រូវស្ថិតក្រោមការទទួលខុសត្រូវ ការត្រួតពិនិត្យ និងការគ្រប់គ្រងដោយផ្ទាល់របស់ប្រធានអង្គភាព។ ប្រធានអង្គភាព (នាយកទីចាត់ការ "សម្រាប់រាជធានី ខេត្ត" ឬប្រធានការិយាល័យ "សម្រាប់ក្រុង ស្រុក ខណ្ឌ")ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល។

ដើម្បីធានានូវគណនេយ្យភាពរបស់ប្រធានអង្គភាពចំពោះនាយករដ្ឋបាល ប្រធានអង្គភាពត្រូវ ៖

- **រៀបចំផែនការសកម្មភាព** ៖ រៀបចំផែនការសកម្មភាពប្រចាំខែ សម្រាប់ទីចាត់ការ ឬការិយាល័យរបស់ខ្លួន (ដោយសម្របសម្រួលជា មួយការិយាល័យចំណុះ "សម្រាប់ថ្នាក់រាជធានី ខេត្ត" ឬមន្ត្រីនៅក្នុងអង្គភាពរបស់ខ្លួន "សម្រាប់ថ្នាក់ក្រុង ស្រុក ខណ្ឌ")។ បន្ទាប់ពីរៀបចំផែនការសកម្មភាព ប្រធានអង្គភាពត្រូវដាក់ផែនការសកម្មភាពប្រចាំខែរបស់ខ្លួនជូននាយករដ្ឋបាល។ នាយករដ្ឋបាលត្រូវពិនិត្យ និងផ្តល់យោបល់លើផែនការសកម្មភាពរបស់អង្គភាព។ ផ្អែកតាមផែនការសកម្មភាពរបស់អង្គភាពនីមួយៗ នាយករដ្ឋបាលត្រូវរៀបចំផែនការសកម្មភាពរបស់រដ្ឋបាលខ្លួន ដើម្បីដាក់ជូនអភិបាលពិនិត្យ និងផ្តល់យោបល់មុនពេលដាក់ជូនក្រុមប្រឹក្សា។
- **អនុវត្តផែនការសកម្មភាព** ៖ ប្រធានអង្គភាពត្រូវចាត់ចែង និងសម្របសម្រួលជាមួយការិយាល័យ ឬមន្ត្រីចំណុះអង្គភាពរបស់ខ្លួន ដើម្បីអនុវត្តសកម្មភាពស្របតាមផែនការដែលបានឯកភាព។ ក្នុងការអនុវត្តជាក់ស្តែង ប្រធានអង្គភាពអាចពិគ្រោះ ពិភាក្សាជាមួយនាយកនាយករងរដ្ឋបាល ឬជាមួយគណៈអភិបាលតាមការចាំបាច់។
- **ការរាយការណ៍** ៖ ប្រធានអង្គភាពត្រូវរាយការណ៍អំពីលទ្ធផលនៃការអនុវត្តផែនការសកម្មភាពប្រចាំខែរបស់ខ្លួនជូននាយករដ្ឋបាល។ ជាមួយគ្នានេះ ក្នុងអំឡុងពេលអនុវត្ត ប្រធានអង្គភាពក៏អាចរាយការណ៍ជាបន្តបន្ទាប់ជូននាយករដ្ឋបាល តាមការចាំបាច់។ ប្រធានអង្គភាពនីមួយៗ

ត្រូវឆ្លើយបំភ្លឺ ឬបកស្រាយអំពីការអនុវត្តផែនការសកម្មភាពរបស់ខ្លួន ឬលទ្ធផលនៃការអនុវត្តរបស់ខ្លួនជូននាយករដ្ឋបាល ក្រុមប្រឹក្សា ឬ គណៈអភិបាលនៅពេលមានការស្នើសុំ។

**បញ្ជាក់ ៖** ក្នុងអំឡុងពេលអនុវត្តតួនាទី ភារកិច្ច និងផែនការសកម្មភាពរបស់ខ្លួន រដ្ឋបាល (អភិបាល អភិបាលរង គណៈកម្មាធិការនានា នាយក នាយករងរដ្ឋបាល នាយក នាយករងទីចាត់ការ ប្រធាន អនុប្រធានការិយាល័យ ព្រមទាំងមន្ត្រី) ត្រូវមានគណនេយ្យភាពតាមឋានានុក្រម និងអាចមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាតាមការចាំបាច់។

## ៣.២.៥. គណនេយ្យភាពរបស់ស្មៀនចំពោះមេឃុំ ចៅសង្កាត់

ស្មៀនឃុំ សង្កាត់ គឺជាមន្ត្រីស្ថិតក្នុងក្របខ័ណ្ឌលេខាធិការរដ្ឋបាលក្រសួងមហាផ្ទៃ។

ស្មៀនឃុំ សង្កាត់ត្រូវធ្វើជាសេនាធិការដល់ក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនក្នុងការ ៖

- ពិនិត្យឡើងវិញនូវ លិខិត និងសំណុំឯកសារទាំងអស់ដែលបានរៀបចំដោយ ឬក្នុងនាមក្រុមប្រឹក្សាឃុំ សង្កាត់ មុនពេលឯកសារទាំងនោះផ្ញើចេញ ឬដាក់ជូនក្រុមប្រឹក្សាឃុំ សង្កាត់ ឬគណៈកម្មាធិការនានា ដើម្បីធានាឲលិខិត ឬឯកសារទាំងនោះមានលក្ខណៈត្រឹមត្រូវតាមនីតិវិធី និងច្បាប់

- កត់ត្រា និងការថែរក្សា ការពារចលនវត្ថុ និងអចលនវត្ថុទាំងអស់ដែលជាទ្រព្យសម្បត្តិឯកជនរបស់ ឃុំ សង្កាត់ ឬជាទ្រព្យសម្បត្តិ ដែលឃុំ សង្កាត់បានជួល។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់
- ធ្វើសេចក្ដីសម្រេច និងអនុវត្តសេចក្ដីសម្រេចនានា ដោយអនុលោមទៅតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលមានជាធរមាន
- ។ល។

លើសពីនេះទៀត ស្មៀនឃុំ សង្កាត់ត្រូវជួយក្រុមប្រឹក្សាឃុំ សង្កាត់អនុវត្តកិច្ចការរដ្ឋបាល ការធានាឲមាននីត្យានុកូលភាពនៃការអនុវត្តអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ និងគណៈកម្មាធិការនានា ការអនុវត្តនិងការតាមដានការអនុវត្តសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ និងការផ្សព្វផ្សាយព័ត៌មានជាសាធារណៈ ជាដើម។

តាមន័យនេះ ស្មៀនឃុំ សង្កាត់ត្រូវទទួលខុសត្រូវដោយផ្ទាល់ចំពោះក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន និងមានការទទួលខុសត្រូវចំពោះក្រសួងមហាផ្ទៃ និងអាជ្ញាធររដ្ឋផងដែរ។

## ៣.៣. គណនេយ្យភាពរបស់រដ្ឋបាលចំពោះប្រជាពលរដ្ឋ

មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ មានតួនាទីផ្ដល់សេវាសាធារណៈជូនប្រជាពលរដ្ឋទាំងបុរស ស្ត្រី និងក្រុមជនងាយរងគ្រោះ។ សេវាសាធារណៈ គឺជាសកម្មភាពទាំងឡាយណា ដែលធ្វើឡើងដោយស្ថាប័នមានសមត្ថ

កិច្ច និងស្ថាប័នទទួលសមត្ថកិច្ចក្នុងគោលដៅបម្រើផលប្រយោជន៍សាធារណៈ។

ដើម្បីបម្រើប្រជាជនកាន់តែល្អប្រសើរឡើង មន្ត្រីរាជការស៊ីវិលគ្រប់រូបចាំបាច់ត្រូវបំពេញការងារប្រកបដោយឆន្ទៈ ម្ចាស់ការ ភក្តីភាព មនសិការវិជ្ជាជីវៈ និងត្រូវមានវប្បធម៌សេវាសាធារណៈ នឹងធ្វើឲការផ្តល់សេវារបស់រដ្ឋបាលសាធារណៈកាន់តែមានតម្លាភាព ភាពឆ្លើយតប និងប្រសិទ្ធភាព។ ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន មន្ត្រីរាជការទាំងអស់មានកាតព្វកិច្ចគោរពច្បាប់ បទបញ្ញា និងសេចក្តីណែនាំនានារបស់ថ្នាក់ដឹកនាំខ្លួន និងមានការទទួលខុសត្រូវផ្ទាល់ចំពោះសកម្មភាពរបស់ខ្លួន។

ដើម្បីសម្រេចគោលបំណងក្នុងការបម្រើប្រជាពលរដ្ឋឲបានកាន់តែល្អប្រសើរឡើង មន្ត្រីរាជការនៅថ្នាក់ក្រោមជាតិ ពិសេសមន្ត្រីរាជការនៅតាមសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ដែលជាអ្នកផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ត្រូវយកចិត្តទុកដាក់ទៅលើ ៖

- **ការផ្តល់ភាពងាយស្រួលក្នុងការទទួលយកសេវារបស់ប្រជាពលរដ្ឋ** ៖ តាមរយៈការផ្តល់ព័ត៌មានគ្រប់គ្រាន់ ច្បាស់លាស់ និងងាយយល់ ព្រមទាំងត្រូវកាត់បន្ថយនូវការិយាធិបតេយ្យ និងនីតិវិធីស្មុគស្មាញនានា សំដៅកាត់បន្ថយការលំបាករបស់អ្នកប្រើប្រាស់សេវា ក្នុងការស្វែងរកសេវាដោយខ្លួនឯង និងការចំណាយបន្ថែមលើអ្នករត់ការក្រៅផ្លូវការ។ អ្នកផ្តល់សេវាសាធារណៈ ត្រូវលើកទឹកចិត្តដល់ប្រជាពលរដ្ឋឲប្រើប្រាស់

សេវាសាធារណៈតាមតម្រូវការរបស់ពួកគេ និងត្រូវដើរតួនាទីជាអ្នកសម្របសម្រួលក្នុងការផ្ដល់ និងទទួលសេវាផងដែរ។

- **តម្លាភាព និងគណនេយ្យភាពក្នុងការផ្ដល់សេវា** ៖ អ្នកផ្ដល់សេវាត្រូវផ្ដល់ព័ត៌មានឱ្យបានទូលំទូលាយ ជាចំហដោយមិនរើសអើង និងយកចិត្តទុកដាក់ផ្ដល់សេវាឱ្យបានទាន់ពេលវេលាកំណត់ និងមានគុណភាពជូនអ្នកប្រើប្រាស់ ដោយស្មារតីទទួលខុសត្រូវខ្ពស់។ ទន្ទឹមនោះ អ្នកផ្ដល់សេវាក៏ត្រូវទុកលទ្ធភាពឱ្យអ្នកប្រើប្រាស់តាមដាន និងស្វែងយល់អំពីនីតិវិធីនៃការផ្ដល់សេវា និងអាចធ្វើការរិះគន់ តវ៉ា ឬទាមទារឱ្យមានការកែលំអលើចំណុចខ្វះខាតផ្សេងៗ តាមតម្រូវការ សំដៅលើកកម្ពស់ប្រសិទ្ធភាព និងតម្លាភាពស្របតាមគោលការណ៍អភិបាលកិច្ចល្អ។
- **គុណភាព និងប្រសិទ្ធភាពនៃសេវា** ៖ អ្នកផ្ដល់សេវា ត្រូវគោរពឱ្យបាននូវស្តង់ដារកំណត់ មានន័យថា អ្វីដែលបានកំណត់ជូនអ្នកប្រើប្រាស់ត្រូវតែធ្វើឱ្យបានតាមការកំណត់នោះ ទាំងតម្លៃ ទាំងពេលវេលា និងគុណភាព។ គុណភាពនៃសេវាត្រូវបានកំណត់ផ្អែកលើការពេញចិត្តរបស់អ្នកប្រើប្រាស់សេវាកម្រិតនៃការឆ្លើយតបទៅនឹងតម្រូវការ និងផលប្រយោជន៍ទូទៅរបស់អ្នកប្រើប្រាស់។
- **តម្រូវការជាក់ស្តែងរបស់អ្នកប្រើប្រាស់សេវា** ៖ កន្លងមកមន្ត្រីរាជការផ្ដល់សេវាក្នុងតរិយាបថជា **អ្នកគ្រប់គ្រង** និងបានកំណត់ជាស្រេចនូវប្រភេទសេវា ដែលត្រូវផ្ដល់ជូនអ្នកប្រើ

ប្រាស់ ទោះជាសេវាមួយចំនួនអ្នកប្រើប្រាស់មិនត្រូវការក៏ដោយ។ ប៉ុន្តែក្នុងស្ថានភាពបច្ចុប្បន្ននេះ មន្ត្រីរាជការត្រូវផ្តល់សេវាក្នុងឥរិយាបថជា **អ្នកផ្តល់សេវា** ដោយត្រូវកំណត់ប្រភេទសេវាទៅតាមតម្រូវការរបស់អ្នកប្រើប្រាស់សេវាវិញ។

ក្រៅពីនេះ ក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ មន្ត្រីរាជការក៏ត្រូវពិចារណាលើចំណុចមួយចំនួនបន្ថែមទៀត ដូចជា ៖

- ការផ្តល់សេវាដោយមានភាពគួរសម រួសរាយ រាក់ទាក់ និងការយកចិត្តទុកដាក់ចំពោះអ្នកប្រើប្រាស់សេវា
- ការផ្តល់ចម្លើយសាមញ្ញ ងាយយល់និងទាន់ពេលវេលា
- ការផ្តល់ការឆ្លើយបំភ្លឺនូវរាល់ការទាមទារ ការតវ៉ា ឬសំណូមពររបស់អ្នកប្រើប្រាស់សេវាឱបានច្បាស់លាស់ និងសមហេតុផល និងតាមស្ថានភាពជាក់ស្តែង
- ...។ល។

## ៣.៤. គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានផ្តល់សិទ្ធិអំណាចដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេច ដែលចេញដោយក្រុមប្រឹក្សា ដើម្បីធានាថា ដីកា និងសេចក្តីសម្រេចទាំងនោះស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ដូច្នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចធ្វើមោឃភាពសេចក្តីសម្រេចឬស្នើឱ្យក្រុមប្រឹក្សាកែសម្រួលសេចក្តីសម្រេចនានាដែលផ្ទុយនឹងរដ្ឋធម្មនុញ្ញ

ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ថ្នាក់ជាតិ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក៏មានសិទ្ធិអំណាចក្នុងការតាមដានការអនុវត្តតួនាទី និងភារកិច្ច ព្រមទាំងរាល់ការរំលោភអំណាចនានាដែលកើតឡើងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

លើសពីនេះទៀត ច្បាប់រៀបចំអង្គការ ក៏បានផ្តល់សិទ្ធិដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងការរំសាយក្រុមប្រឹក្សាឃុំ សង្កាត់ និងការស្នើទៅរាជរដ្ឋាភិបាលឱ្យធ្វើការរំសាយក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងករណីដែលក្រុមប្រឹក្សាទាំងនោះអនុវត្តផ្ទុយនឹងរដ្ឋធម្មនុញ្ញ គោលនយោបាយ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក៏អាចចេញសេចក្តីណែនាំជាលាយលក្ខណ៍អក្សរ ដើម្បីជំរុញឱ្យក្រុមប្រឹក្សាអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានត្រឹមត្រូវឡើងវិញ ឬអាចគ្រប់គ្រងជំនួសជាបណ្តោះអាសន្នរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អាចស្នើទៅរាជរដ្ឋាភិបាលក្នុងការដកចេញពីមុខតំណែងនូវអភិបាល អភិបាលរងរាជធានី ខេត្ត អភិបាលក្រុង ស្រុក ខណ្ឌ និងអាចសិក្សាស្រាវជ្រាវ និងដកចេញពីមុខតំណែងនូវអភិបាលរងក្រុង ស្រុក ខណ្ឌ តាមសំណើរបស់ក្រុមប្រឹក្សា។ តាមន័យនេះ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ពិសេសគណនេយ្យភាពចំពោះរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ៕